នីតិវិធីព្រហ្មទណ្ឌកម្ពុជា

ស្តីពី

ការបំនុំជម្រះសាលាជាន់ដំបូង



សាលាត្រាជូ

ដោយៈ ចក សម្បត្តិ ជាព្រះរាជអាជ្ញារង និង

ជាអនុប្រធានសមាគមសាលាត្រាជូ

នាំមកសិក្ខាដោយៈ អៀង សំអាង

ការដំនុំជម្រះ
ជាន់សាលាដំបូង

ការនិន្ទ័យក្តី

- ភាពមិនលំអៀង និងការបែងចែកមុខងារ ស៊ើបអង្កេត ស៊ើបសួរ និងជំនុំជម្រះ។ គោលការណ៍នៃការបែងចែកអំណាច ជាមូលដ្ឋានគ្រឹះនៃនីតិរដ្ឋ។
- ម២៨៨ ក២៖ ចៅក្រមណាដែលបានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ឬ ជាចៅក្រមស៊ើបសួរលើរឿងណាមួយ មិនអាចចូលរួមក្នុងការជំនុំជម្រះរឿងនោះបានទេ បើពុំដូច្នោះទេ សាលក្រមនឹងត្រូវទុកជាមោឃៈ។

ការវិនិច្ឆ័យក្តី (បន្ត)

- សមាសភាពជំនុំជម្រះករណី **នីតិជន** ម២៨៩ ម៣៤៨៖
  - ម២៨៩៖ ចៅក្រម ៣ រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទង។
  - ចៅក្រមទោល ករណី បទមជ្ឈិម និងលហុ។
- សមាសភាពជំនុំជម្រះករណី **អនីតិជន** ម៤៤ ច្ប.អនីតិជន៖
  - ម២៨៩៖ ចៅក្រម ៣ រូប **ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទង** និង**បទមជ្ឈិម**
  - ចៅក្រមទោល ករណីលហុ។

ការវិនិច្ឆ័យក្តី (បន្ត)

- ម២៩០ សមត្ថកិច្ចខាងដែនដី៖
  - តុលាការនៃទីកន្លែងប្រព្រឹត្តបទល្មើស
  - តុលាការនៃលំនៅដ្ឋានរបស់ជនជាប់ចោទ ឬ
  - តុលាការនៃទីកន្លែងចាប់ខ្លួនជនជាប់ចោទ
- ករណីវិវាទសមត្ថកិច្ច តុលាការជាន់ខ្ពស់ជាអ្នកសម្រេច៖ អាចជាសាលាឧទ្ធរណ៍ ឬតុលាការកំពូល។

ការជំនុំជម្រះ ជាន់ជំបូង

- លក្ខណៈជាមូលដ្ឋាននៃសវនាការ
  - សាធារណៈភាពនៃសវនាការ
  - ការពិភាក្សាដេញដោលដោយផ្ទាល់មាត់
  - ការបង្ហាញខ្លួនដោយផ្ទាល់ខ្លួនរបស់គូភាគី
  - ការមិនអាចផ្តាស់ប្តូរបានន្ទូរចំណុចវិវាទ (saisine *in rem*)
  - ការមិនអាចបញ្ឈប់ដំណើរការក្តី (l'indisponibilité du procès pénal)

ការជំនុំជម្រះជាន់ជំបូង (បន្ត)

- **ការប្តឹងទៅចៅក្រមជំនុំជម្រះក្តី ម២៩១៖**
  - ករណីមានការស៊ើបសួរ
    - ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះដោយចៅក្រមស៊ើបសួរ ឬសាលដីកាដោយសភាស៊ើបសួរ Ordonnace de renvoie
  - ករណីគ្មានការស៊ើបសួរ
    - កំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម CI
    - ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះដោយផ្ទាល់ CD

ការជំនុំជម្រះជាន់ជំបូង (បន្ត)

- **វិបាកនៃការប្តឹង៖**
  - **ទៅលើបុគ្គល**៖ ម៣៤៩ តុលាការអាចជំនុំជម្រះបុគ្គលដែលបញ្ជូនទៅមុខខ្លួនក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ (ម៤៣ ការចោទប្រកាន់)។
  - **ទៅលើអង្គហេតុ** (កម្មវត្ថុនៃបណ្តឹង) ម៣៤៨ ក១៖
    - កាតព្វកិច្ចពិភាក្សាលើ**អង្គហេតុ** តាមគ្រប់វិចារណកិច្ចគតិយុត្តិដែលអាច លើ**អំពើ**ដែលប្តឹងមកដោយឃុត្តាធិការស៊ើបសួរ ឬព្រះរាជអាជ្ញា
    - ការហាមឃាត់ការជម្រះក្តីលើអង្គហេតុក្រៅពីការប្តឹង
    - កាតព្វកិច្ចជម្រះក្តីលើបណ្តុំនៃអង្គហេតុ (កម្មវត្ថុនៃបណ្តឹង)។

ការដំឡូងជ្រុះជាន់ដំបូង (បន្ត)

- ភាគីនៅចំពោះមុខសាលាជម្រះក្តី៖ មុំបីនៃយុត្តិធម៌
  - –អាជ្ញាធរម្ចាស់បណ្តឹងអាជ្ញា៖
    - អយ្យការ៖ អាចអវត្តមាន ក្នុងករណីសវនាការលើបណ្តឹងរដ្ឋប្បវេណី។
    - ភាគីដែលប្តឹង (អាជ្ញាធរផ្សេងទៀតដែលច្បាប់ផ្តល់អំណាចជូន)។

ការជំនុំជម្រះជាន់ជំបូង (បន្ត)

– ជនល្មើស ឬជនជាប់ចោទ

- ការបង្ហាញខ្លួន មា៣០០។
  - ករណី CD ចូលបង្ហាញខ្លួនដោយសេរី មា៣០២
  - ករណី CI មានកងកម្លាំងសាធារណៈអម មា៣០៣
  - ករណី បញ្ជូនពីយុត្តាធិការស៊ើបសួរ គឺចូលបង្ហាញខ្លួនដោយសេរី លើកលែងតែត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។
- តុលាការអាចបង្គាប់ឲ្យបន្តឃុំខ្លួន រហូតដល់សវនាការចប់ (មា៣០៦) ។

ការជំនុំជម្រះជាន់ជំបូង (បន្ត)

- ជំនួយនៅពេលបង្ហាញខ្លួន៖ មេធាវី ៣០០។ មេធាវីត្រូវមានជាដាច់ខាត ករណីបទឧក្រិដ្ឋ ឬកាលណាជនជាប់ចោទជា**<u>អនីតិជន</u>** ម៣០១។
- អវត្តមាននៃជនជាប់ចោទ៖ ចេញដីកាបង្គាប់ឲ្យនាំខ្លួន (ម៣១០) ឬ ទៅស្នូរជនជាប់ចោទនៅទីកន្លែងដែលជននោះនៅ ប្រសិនបើស្ថានភាពសុខភាព ឬមូលហេតុធ្ងន់ធ្ងរដែលធ្វើឲ្យជនជាប់ចោទអវត្តមាន។

ការដំនុំជម្រះជាន់ដំបូង (បន្ត)

– ដើមបណ្តឹងរដ្ឋប្បវេណី

- ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងពេលសវនាការ និងមុនពេលព្រះរាជអាជ្ញាសន្និដ្ឋានសុំលើអង្គសេចក្តី មា១១។
- ការបង្ហាញខ្លួន និងអាចមានមេធាវីអម និងអាចត្រូវបានតំណាងដោយ មេធាវី សហព័ន្ធ ឬញាតិលោហិតផ្ទាល់ មា១៣។
- ទោះបីអវត្តមាន កាលណាតុលាការប្រកាសពិរុទ្ធភាព តុលាការត្រូវតែសម្រេចឲ្យសងការខូចខាត មា៥៦។
- ការលះបង់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីតាមវិធានរដ្ឋប្បវេណី។

ការបំនុំជម្រះ ជាន់ជំបូង (បន្ត)

– ភាគីដែលជាប់ពាក់ព័ន្ធ

- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- អ្នកធានារ៉ាប់រង
- អាជ្ញាធរផ្សេងទៀត៖ មន្ត្រីសុខាភិបាល ឬមន្ត្រីនគរបាលជំនាញគ្រឿងញៀន ត្រូវចូលរួមសវនាការ។

ការបំនុំជម្រះ ជាន់ជំបូង (មន្ត)

- ការពិភាក្សាដេញដោលក្នុងសវនាការ
  - <u>ការបើកការពិភាក្សាដេញដោល</u>
    - ខ្លឹមសារ និងទម្រង់ការ (ការអានលិខិតចោទប្រកាន់) ការត្រួតពិនិត្យអត្តសញ្ញាណ។
    - ការត្រួតពិនិត្យមើលលើបណ្តឹងដែលបញ្ជូនមក
      - ការបញ្ជូនផ្នែកអង្គហេតុ ឬផ្នែកច្បាប់
      - ការបញ្ជូនទៅលើផលប្រយោជន៍រដ្ឋប្បវេណី
      - ការបញ្ជូនទៅលើការរឹបអូស ម២៤៧ថ្មី។

ការបំនុំជម្រះ ជាន់ជំបូង (មន្ត)

– ការដោះស្រាយក្នុងសមត្ថកិច្ចអញ្ញត្រកម្ម និងបណ្តឹងឧប្បត្តិហេតុ

- កាតព្វកិច្ចត្រូវដោះស្រាយ។
- ដែនអនុវត្តន៍នៃបណ្តឹងឧប្បត្តិហេតុ៖
  - សមាសភាពតុលាការ
  - វិធានការស៊ើបអង្កេត
  - ការឃុំខ្ជួនបណ្តោះអាសន្ន។
- អញ្ញត្រកម្មដែលលើកឡើងដោយចៅក្រម ឬ ភាគី។

– ការបិទការពិភាក្សាដេញដោល ម៣២២ - ម៣៤១។

សាលក្រមជាន់ដំបូង (បន្ត)

- <u>ការប្រកាសសាលក្រម (ជាសាធារណៈ)</u>
  - សម្រេចឲ្យរួចទោស កាលណាគ្មានបទល្មើស៖ វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ។
    - ម៤៩ ច្ប,អនីតិជន ករណីរកឃើញថា អនីតិជនជាប់ចោទមានអាយុក្រោម ១៤ ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស (ទោះបីមានប្រព្រឹត្តបទល្មើសក៏ដោយ) តុលាការត្រូវសម្រេចឲ្យអនីតិជនរួចផុតពីការចោទប្រកាន់ និងបង្គាប់ឲ្យដោះលែងជាបន្ទាន់។ តែក្នុងករណីអនីតិជននោះបានប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចអំពីសំណងរដ្ឋប្បវេណី កាលណាមានបណ្តឹងទាមទារ។

សាលក្រមជាន់ដំបូង (បន្ត)

- សម្រេចផ្តន្ទាទោស កាលណារកឃើញពិរុទ្ធភាព មា៥០។
- ម៥២ ក៨ ច្ប,អនីតិជន ករណីអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ជាប់ចោទពីបទលហុ ឬបទមជ្ឈិម ឬមជ្ឈិមមានស្ថានទម្ងន់ទោស កាលណាការបង្ហែទទួលបានជោគជ័យ តុលាការត្រូវចេញសាលក្រមឲ្យអនីតិជន *មិនទទួលខុសត្រូវព្រហ្មទណ្ឌ*។ តុលាការអាចចេញសាលក្រមអំពីសំណងរដ្ឋប្បវេណី ក្នុងករណីមានការប្តឹងសុំ។
- ក្នុងសាលក្រមតែមួយ តុលាការសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ៣៥៥។

សាលក្រមជាន់ដំបូង (បន្ត)

- ការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវបញ្ឈប់នៅពេលប្រកាសសាលក្រម មា៥២។
- បើប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារ ១ ឆ្នាំ យ៉ាងតិច ដោយគ្មានការព្យួរទោសទេ តុលាការអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ឬបង្គាប់ឲ្យនាំខ្លួន មា៥៣។
- តុលាការមានសមត្ថកិច្ចសម្រេចអំពីការប្រគល់វត្ថុដែលចាប់យក មា៥៤។
- សាលក្រមអាចជាសាលក្រមចំពោះមុខ ឬសាលក្រមកំបាំងមុខ។